01200817

E347/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 02 / 2016
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យពិចារណាឡើងវិញក្នុងការទទួលយកអត្ថបទដកស្រង់មួយ និងទទួលយកអត្ថបទដកស្រង់ចំនួនពីរបន្ថែមទៀតពីរបាយការណ៍ អង្គការឃ្លាំមើលសិទ្ធិមនុស្ស "រយៈពេល៣០ឆ្នាំនៃការកាន់តំណែងរបស់ ហ៊ុន សែន"**

១. អង្គជំនុំជម្រះបានទទួលសំណើមួយចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ពីក្រុមមេធាវីការពារក្តី នួន ជា ("សំណើ") សុំឱ្យអង្គជំនុំជម្រះ ១) ពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួន E347/1 ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ដែលបានបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំឱ្យទទួលយកជាភ័ស្តុតាងនូវជំពូក II នៃរបាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលមានចំណងជើងថា "រយៈពេល៣០ឆ្នាំ នៃការកាន់តំណែងរបស់ ហ៊ុន សែន៖ អំពើហិង្សា ការបង្ក្រាប និងអំពើពុករលួយក្នុងប្រទេសកម្ពុជា" ចេញផ្សាយខែ មករា ឆ្នាំ ២០១៥ ("របាយការណ៍ HRW") និង ២) ទទួលយកជាភ័ស្តុតាងនូវជំពូក III និង IX នៃ

របាយការណ៍ដដែលនេះ អនុលោមតាម វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E347/2 កថាខណ្ឌ ១) ។ ភាគីដទៃទៀតមិនបានធ្វើសារណាឆ្លើយតបឡើយ។

២. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង សម្រេច៖

ក. <u>បដិសេធ</u> សំណើថ្មីសុំឱ្យទទួលយកជាភ័ស្តុតាងនូវជំពូក II នៃរបាយការណ៍ HRW។

ខ. <u>បដិសេធ</u> សំណើសុំឱ្យទទួលយកជាភ័ស្តុតាងនូវជំពូក III និង ជំពូក IX នៃរបាយការណ៍ HRW។

៣. សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះ នឹងចេញក្នុងពេលសមស្របខាងមុខ។